# អនុក្រឹត្យលេខ ១៨ អនក្រ បក
## ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

*****

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨០ ចុះថ្ងៃទី៣១ ខែតុលាឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជននិងកីឡា

-យោងកិច្ចព្រមព្រៀងចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី

-យោងអនុស្សរណៈនៃការយល់ដឹង ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

-បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨

## សំរេច

**មាត្រា ១.-** បង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលហៅកាត់ថា "គ.ជ.ប.ប" ដើម្បីសំរបសំរួលជាមួយក្រសួង-ស្ថាប័នអង្គការនានាដែលពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ឲ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ចបច្ចុប្បន្ន និងទៅអនាគត នៅកម្ពុជា ។

**មាត្រា ២.-** សមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាលមានដូចខាងក្រោម :

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា | ជាប្រធាន |
| ២- តំណាងក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន | អនុប្រធាន |
| ៣- តំណាងនិយោជក | អនុប្រធាន |
| ៤- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |

www.pheakdeylaw.com

៥- តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
៦- តំណាងក្រសួងសុខាភិបាល សមាជិក
៧- តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល សមាជិក
៨- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
៩- តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
១០- តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក
១១- តំណាងក្រសួងទេសចរណ៍ សមាជិក
១២- តំណាងក្រសួងកិច្ចការនារី សមាជិក
១៣- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
១៤- តំណាងក្រសួងផែនការ សមាជិក
១៥- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
១៦- តំណាងក្រសួងបរិស្ថាន សមាជិក
១៧- តំណាង ៥រូប របស់និយោជក សមាជិក
១៨- តំណាង ១ រូបរបស់សភាពាណិជ្ជកម្ម សមាជិក
១៩- តំណាង ២ រូបរបស់និយោជិក សមាជិក
២០- តំណាង ៣ រូប ជាអ្នកផ្តល់ការបណ្តុះបណ្តាល សមាជិក

-គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៧រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ចូលរួមបាន។

-គណៈកម្មាធិការជាតិនេះ មាននាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈនៃក្រសួងអប់រំយុវជននិងកីឡាជាលេខាធិការអចិន្ត្រៃយ៍ ។

**មាត្រា ៣ .-** គណៈកម្មាធិការជាតិនេះមានភារកិច្ច :

-រៀបចំគោលនយោបាយ និង គំរោងផែនការជាតិសំរាប់អប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ។

-សំរបសំរួលនិងតំរង់ទិសការងារបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។

-លើកគំរោងកែទំរង់ និងអភិវឌ្ឍន៍ប្រព័ន្ធអប់រំ និង បណ្តុះបណ្តាល បច្ចេកទេស និង វិជ្ជាជីវៈ ដើម្បីឲ្យក្លាយជាប្រព័ន្ធមួយដែល :

-មានគុណភាពនិងប្រសិទ្ធភាពខ្ពស់

-ផ្សារភ្ជាប់ទៅនឹងអាទិភាពនៃការអភិវឌ្ឍន៍ជាតិ

-ឆ្លើយតបទៅនឹងតម្រូវការរបស់ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ។ល។

-មានទំនាក់ទំនងរវាងកន្លែងធ្វើការងារ និង គ្រឹះស្ថានបណ្តុះបណ្តាល

មាត្រា ៤.- គណៈកម្មាធិការជាតិ ត្រូវជ្រើសតាំងសមាជិករបស់ខ្លួន ៩រូប ធ្វើជាគណៈកម្មាធិការប្រតិបត្តិ ដែលមានសមាសភាពដូចខាងក្រោម ៖

-រដ្ឋម ន្ត្រីក្រសួងអប់រំយុវជននិងកីឡា ប្រធាន

-តំណាងក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន អនុប្រធាន

-តំណាង ២ រូប របស់ក្រសួង ឬស្ថាប័នរដ្ឋាភិបាល សមាជិក

-តំណាង ២ រូប របស់និយោជក សមាជិក

-តំណាង ១រូប របស់និយោជិក សមាជិក

-តំណាង ១រូប របស់ស្ថានកផ្តល់ការបណ្តុះបណ្តាល សមាជិក

-គណៈកម្មការប្រតិបត្តិ អាចអញ្ជើញតំណាង១រូបរបស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលចូលរួម ។

-គណៈកម្មការប្រតិបត្តិនេះ មានមន្ត្រីប្រតិបត្តិម្នាក់ធ្វើជាលេខាធិការដ្ឋាន ។

មាត្រា ៥ .- គណៈកម្មការប្រតិបត្តិនេះមានភារកិច្ចៈ

-គ្រប់គ្រងក្នុងនាមគណៈកម្មាធិការជាតិ នូវមូលនិធិជាតិបណ្តុះបណ្តាលរៀបចំកម្មវិធី និងរបៀបវារៈប្រជុំរបស់គណៈកម្មាធិការជាតិ

-លើកសំណើដែលពាក់ព័ន្ធដល់ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈជូនគណៈកម្មាធិការជាតិ ពិនិត្យនិងសំរេច ។

មាត្រា ៦.- នៅតាមខេត្ត-ក្រុង ត្រូវបង្កើតឲ្យមានគណៈកម្មាធិការសំរបសំរួលការងារអប់រំបណ្តុះបណ្តាល បច្ចេកទេសវិជ្ជាជីវៈ ថ្នាក់ខេត្ត-ក្រុង ដែលហៅកាត់ថា គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ។ សមាសភាពគណៈកម្មាធិការនេះរួមមាន អភិបាលខេត្ត-ក្រុងជាប្រធាន ប្រធានមន្ទីរអប់រំយុវជន និងកីឡាជាអនុប្រធាន ប្រធានមន្ទីរពាក់ព័ន្ធតំណាងអង្គការអន្តរជាតិនិងអង្គការ ក្រៅរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិក និងតំណាងអ្នកផ្តល់ការបណ្តុះបណ្តាលជាសមាជិក ហើយមានការិយាល័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់មន្ទីរ អប់រំយុវជន និងកីឡាខេត្តក្រុងជាលេខាធិការដ្ឋាន ។

មាត្រា ៧.- ភារកិច្ចរបស់គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ត្រូវកំណត់ក្នុងលក្ខន្តិកៈដោយគណៈកម្មាធិ-ការជាតិបណ្តុះបណ្តាល ។

មាត្រា ៨.- គណៈកម្មាធិការជាតិបណ្តុះបណ្តាល មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងអប់រំយុវជន និងកីឡា ។

មាត្រា ៩.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

មាត្រា ១០.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង គណៈកម្មាធិការជាតិបណ្តុះបណ្តាល មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

***

# អនុក្រឹត្យលេខ ១៩ អនក្រ.បក

## ស្តីពី

## ការលុបអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៩៧ដែលស្តីពីការរៀបចំ ឲ្យដំណើរការឡើងវិញនូវក្រុមហ៊ុនអាកាសចរកម្ពុជា

*****

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល

-យោងតាមសំណូមពរចាំបាច់

## សំរេច

មាត្រា ១.- អនុក្រឹត្យលេខ៣០ អនក្រ/បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ ដំណើរការឡើងវិញនូវក្រុមហ៊ុនអាកាសចរកម្ពុជា (KAMPUCHEA AIRLINE) អក្សរកាត់ (KAL) ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២.- អនុញ្ញាត ឲ្យក្រុមហ៊ុនអាកាសចរកម្ពុជា ( KAMPUCHEA AIRLINES) អក្សរកាត់ (KAL) រៀបចំបែបបទ ដើម្បីឲ្យក្រុមហ៊ុននេះប្រែក្លាយទៅជាក្រុមហ៊ុនឯកជន ។

www.pheakdeylaw.com